ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២២ លេខ ២ ខែមិថុនា ២០១៨ តម្លៃ ១.៥០០៛

# ទំនុកចិត្តលើក្រុមប្រឹក្សាឃុំសង្កាត់នៅកម្ពុជា



*ក្រុមប្រឹក្សាឃុំសង្កាត់មានប្រជាប្រិយភាព និងទទួលបានការគោរពពីប្រជាជនកម្ពុជាភាគច្រើន ដោយសារតួនាទីគាត់ក្នុងការអភិវឌ្ឍនៅតាមមូលដ្ឋាន ការដោះស្រាយទំនាស់ ភ្នំពេញ ខែឧសភា ២០១៨*

## សេចក្ដីផ្ដើម

នៅកម្ពុជា ក្រុមប្រឹក្សាឃុំសង្កាត់បានកើតមានឡើងជាផ្លូវការ តាមការបោះឆ្នោតឃុំ/សង្កាត់លើកទី១ នៅខែកុម្ភៈ ២០០២។ ក្រុមប្រឹក្សានេះមានសិទ្ធិអំណាចធំទូលាយក្នុងការជំរុញការអភិវឌ្ឍក្នុងឃុំ និងជាអ្នកតំណាងដើម្បីលើកពីតម្រូវការរបស់ប្រជាជនម្ចាស់ឆ្នោត ក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។ ប៉ុន្តែឃុំជួបនឹងបញ្ហាប្រឈមធំៗមួយចំនួន ដោយសារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល មិនបានដំណើការជឿនលឿនដូចការរំពឹងទុក ដូចមានបញ្ជាក់ក្នុងកម្មវិធីជាតិ១០ឆ្នាំសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិពីឆ្នាំ២០១០-២០១៩។ ទោះបីមានការចោទសួររបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានពីលទ្ធផលការងារក្ដី ក៏ឃុំនៅតែបន្តទទួលបានការគោរពកម្រិតខ្ពស់ និងទំនុកចិត្តខ្លាំងជាងគេ ក្នុងចំណោមរដ្ឋអំណាចកម្រិតផ្សេងៗនៅកម្ពុជា។ តាមអង្កេតមួយដែលវិទ្យាស្ថាន CDRI ធ្វើឡើងក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋបានដាក់ពិន្ទុខ្ពស់សម្រាប់ទំនុកចិត្តលើក្រុមប្រឹក្សាឃុំសង្កាត់ បើធៀបនឹងស្ថាប័នសាធារណៈដទៃទៀត។ លទ្ធផលរកឃើញនេះ ផ្អែកលើទិន្នន័យអង្កេតតំណាងឲ្យទូទាំងប្រទេសក្នុងឆ្នាំ២០១៧ លើប្រជាពលរដ្ឋកម្ពុជា ហើយវាស្របគ្នានឹងលទ្ធផលរកឃើញក្នុងការសិក្សាមុនៗ[1] ដែលធ្វើឡើងក្រោយការបោះឆ្នោតឃុំសង្កាត់លើកទី១។ លទ្ធផលនេះផ្ដល់គំនិតថា វិមជ្ឈការនៅកម្រិតឃុំ បានចូលរួមចំណែកពិតប្រាកដដល់ការកសាងទំនុកចិត្តលើរដ្ឋអំណាច និងទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងរដ្ឋនឹងប្រជាពលរដ្ឋ។ ចំណូលចិត្តចំពោះមន្ត្រីក្នុងមូលដ្ឋានក៏ឆ្លុះបញ្ចាំងពី បែបបទដែលអ្នកភូមិកសាងទំនាក់ទំនងជាមួយរដ្ឋអំណាចឃុំ ជាសំខាន់តាមរយៈទំនាក់ទំនងជាបុគ្គល ជាជាងជាលក្ខណៈស្ថាប័ន។ អត្ថបទនេះ ធ្វើការសន្និដ្ឋានដោយផ្ដល់មតិពីវិធីជួយគាំទ្រ និងពង្រឹងថែមទៀតនូវទំនុកចិត្តទៅលើឃុំ ដើម្បីលើកកម្ពស់ការចូលរួមបំពេញកាតព្វកិច្ចជាពលរដ្ឋ និងលទ្ធផលការងាររបស់រដ្ឋអំណាចមូលដ្ឋាន។

## ក្រុមប្រឹក្សាឃុំសង្កាត់នៅកម្ពុជា

ការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០០២ បានកំណត់ការធ្វើកំណែទម្រង់វិមជ្ឈការជាផ្លូវការនៅកម្ពុជា។ គេតែងគិតថា ការបោះឆ្នោតធ្វើឲ្យរដ្ឋអំណាចមូលដ្ឋានកាន់តែជិតស្និទ្ធជាមួយប្រជាពលរដ្ឋ ហើយ

## មាតិកា

ទំនុកចិត្តលើក្រុមប្រឹក្សាឃុំសង្កាត់នៅកម្ពុជា ........................ ១
ទំនាក់ទំនងរវាងយុវជន នឹងមនុស្សជំនាន់មុននៅកម្ពុជា.......... ៧
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ...................... ១៥
– ស្ថានភាពក្នុងប្រទេស....................... ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ................................... ២៤

អត្ថបទនេះ រៀបរៀងដោយ អេង នេត្រា ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ និងជាប្រធានផ្នែកអភិបាលកិច្ច នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Eng Netra. 2018. “Trust in Commune Councils in Cambodia.” *Cambodia Development Review* 22 (2): 1-6. ភ្នំពេញ វិទ្យាស្ថាន CDRI។

[1] See Ninh and Henke 2005, and FitzGerald and So 2007.

ទទួលបានព័ត៌មានពីតម្រូវការនិងសំណើរបស់ប្រជាជន ដូច្នេះអាចឆ្លើយតបបានកាន់តែប្រសើរទៅនឹង តម្រូវការក្នុងមូលដ្ឋាន។ កំណែទម្រង់វិមជ្ឈការ បាននាំមកនូវការផ្លាស់ប្តូរសំខាន់ៗនៅកម្រិតឃុំ។ ជាលើកទី១ ហើយ ដែលប្រជាជនក្នុងឃុំសង្កាត់បានបោះឆ្នោតជ្រើសរើស សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ដោយផ្ទាល់ នាំឲ្យមានអ្នកតំណាង មកពីគណបក្សនយោបាយចម្រុះៗជាច្រើនជាប់ឆ្នោតចូលក្នុងក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការបោះឆ្នោតនៅឆ្នាំ២០០២ ២០០៧ និង ២០១២។[២] កន្លងមក ក៏មានការផ្លាស់ប្តូរជាសំខាន់ក្នុងមុខងាររបស់ក្រុមប្រឹក្សាឃុំដែរ តាំងពីតួនាទីនិងទំនួលខុសត្រូវផ្តោតលើសន្តិសុខក្នុងទសវត្សរ៍១៩៩០ រហូតដល់ទំនួលខុសត្រូវ និង សកម្មភាពផ្តោតលើការអភិវឌ្ឍ។ សព្វថ្ងៃនេះ ឃុំទទួលខុសត្រូវគ្រប់គ្រងលើការធ្វើផែនការអភិវឌ្ឍន៍ដោយមានការចូលរួម ដើម្បីកំណត់ និងអនុវត្តគម្រោងអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានផ្សេងៗ ដោយប្រើមូលនិធិផ្ទេរមកពីថ្នាក់ជាតិ ហៅថាមូលនិធិឃុំសង្កាត់ (CSF)។ ឃុំក៏មានភារកិច្ចផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋាន ចុះបញ្ជីអ្នកបោះឆ្នោត និងជួយសម្រុះសម្រួលទំនាស់ក្នុងមូលដ្ឋានផងដែរ។

ការសិក្សាស្រាវជ្រាវបានរកឃើញថា ក្រុមប្រឹក្សាឃុំសង្កាត់ជួបការលំបាកមួយចំនួនក្នុងការអនុវត្តមុខងាររបស់ខ្លួន ពីព្រោះត្រូវតំណាងឲ្យ និងឆ្លើយតបនឹងក្តីរំពឹងរបស់ម្ចាស់ឆ្នោត (Rusten et al. 2004; NCDDS 2012; World Bank 2013; Eng 2016)។ ការលំបាកនេះបង្កឡើងជាសំខាន់ដោយសារ កត្តា ៣ ។ ទី១ ថវិកាឃុំនៅតែពឹងផ្អែកលើ មូលនិធិផ្ទេរមកពីថ្នាក់ជាតិ ហើយនៅតូចនៅឡើយ ទោះបីកំពុងកើនឡើងជាបណ្តើរៗក្តី។ ក្នុង ១៦ឆ្នាំកន្លងមកនេះ ចំណែកនៃថវិកាជាតិដែលបែងចែកទៅឲ្យមូលនិធិឃុំសង្កាត់ បានកើនពីត្រឹម ២% នៃចំណូលក្នុងស្រុកនៅឆ្នាំ២០០២ រហូតដល់ ៣% ក្នុងឆ្នាំ២០១៨។ មូលនិធិនេះ បានផ្តល់ឲ្យក្រុមប្រឹក្សាឃុំសង្កាត់នូវសិទ្ធិអំណាចសម្រេចអារកាត់ ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ឃុំរៀងៗខ្លួន។ មកទល់ពេលនេះ ឃុំផ្តោតលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដូចជា ការថែទាំផ្លូវថ្នល់ និងការជួសជុលប្រព័ន្ធធារាសាស្ត្រជាដើម។ កន្លងមកមានការរីកចម្រើនខ្លះដែរលើការអនុវត្ត ច្បាប់ស្តីពីរដ្ឋបាល និងការគ្រប់គ្រងឃុំសង្កាត់ឆ្នាំ២០០១ ជាពិសេស សេចក្តីថែងដែលអនុញ្ញាតឲ្យក្រុមប្រឹក្សាឃុំសង្កាត់ប្រមូលចំណូល និងពន្ធដាររបស់ខ្លួនផ្ទាល់។ តាំងពីឆ្នាំ២០១៨ មក ឃុំបានទទួលចំណែក ១% នៃចំណូលពន្ធរបស់ខេត្ត ហើយឃុំក៏ប្រមូលយកផងដែរនូវ ប្រាក់កម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន និងសេវារដ្ឋបាលផ្សេងទៀត។ ប៉ុន្តែចំណូលទាំងនេះមានចំនួនតិចតួចណាស់ ដូច្នេះហើយមូលនិធិឃុំសង្កាត់នៅតែជាប្រភពចំណូលចម្បងដដែល។ ការសិក្សានានាបានបង្ហាញដូចគ្នាថា ប្រភពចំណូលមានកម្រិត គឺជាឧបសគ្គចម្បងរារាំងក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការបំពេញតួនាទីរបស់ខ្លួន ដើម្បីជំរុញការអភិវឌ្ឍក្នុងមូលដ្ឋាន និងក្នុងការបង្ហាញឲ្យគេឃើញថាឃុំសង្កាត់មានគណនេយ្យភាពចំពោះម្ចាស់ឆ្នោត (Kim 2012; Mansfield and Macleod 2004; Öjendal and Kim 2011; Rusten et al. 2004; World Bank 2012)។

ទី២ ការផ្ទេរមុខងារពីថ្នាក់ក្រសួង មកថ្នាក់ស្រុក មានការជឿនលឿនតិចតួចណាស់ ហើយបញ្ហានេះមានផលពាក់ព័ន្ធច្រើនដល់សិទ្ធិអំណាច និងគណនេយ្យភាពរបស់ឃុំក្នុងការជំរុញការផ្តល់សេវាសាធារណៈដ៏ចាំបាច់ៗ (Eng 2016; NCDDS 2012; Particip Consortium 2016)។ បញ្ហានេះអាចមកពីឃុំជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាស្រុក ហើយគេរំពឹងថាឃុំអាចតំណាងឲ្យតម្រូវការក្នុងឃុំនៅឯថ្នាក់ស្រុក ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌឆ្នាំ២០០៨។ ទោះបីមានការអំពាវនាវជាបន្តបន្ទាប់អំពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទៅដល់ក្រសួងជំនាញនានាឲ្យផ្ទេរមូលនិធិទៅឲ្យកម្រិតស្រុកក្តី កិច្ចប្រឹងប្រែងនេះត្រូវរាំងស្ទះដោយសារភាពស្មុគ្រស្មាញនៃការងារ និងការលំបាកក្នុងការសម្របសម្រួលក្រសួងជំនាញផ្សេងៗ។ ការអនុវត្តផែនការដំណាក់កាលទី៣ សម្រាប់កម្មវិធីជាតិ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៨-២០ បានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការផ្ទេរទំនួលខុសត្រូវច្រើនថែមទៀតទៅឲ្យថ្នាក់ស្រុក។ ការរីកចម្រើនមកទល់សព្វថ្ងៃបានផ្តល់គំនិតថា ជាជាងការផ្ទេរមុខងារនេះ គ្រប់ការិយាល័យរបស់ក្រសួងជំនាញនៅតាមស្រុក នឹងត្រូវដាក់បញ្ចូលទៅក្នុងរដ្ឋបាលស្រុក។ គំនិតផ្តួចផ្តើមនេះរំពឹងថា នឹងចាប់អនុវត្តនៅឆ្នាំ២០២០ ។

ទី៣ ឃុំត្រូវជួបឧបសគ្គ ដោយសារមានសមត្ថភាពនៅខ្សោយក្នុងការបំពេញមុខងាររបស់ខ្លួន និងធ្វើការពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ (COMFREL 2007; NCDDS 2012; Particip Consortium 2016)។ តាំងពីឆ្នាំ២០០២ មក ការបោះឆ្នោតបានផ្លាស់ចេញពីក្រុមប្រឹក្សាឃុំសង្កាត់នូវ មន្ត្រីមូលដ្ឋានគ្មានប្រជាប្រិយភាពមួយចំនួន និងជ្រើសចូលវិញនូវអ្នកមានប្រជាប្រិយភាពជាងមុន។ ទោះយ៉ាងនេះក្តី អាសនៈក្នុងក្រុមប្រឹក្សាឃុំសង្កាត់ តែងកាន់កាប់ភាគច្រើនដោយបុរសវ័យចំណាស់ដែលធ្លាប់ធ្វើការរាប់សិបឆ្នាំក្នុងក្រុមអ្នកដឹកនាំក្នុងមូលដ្ឋាន។ ពួកគាត់ជារឿយៗមានកម្រិតវប្បធម៌ទាប និងការបណ្តុះបណ្តាលជាផ្លូវការ ព្រោះជំនាន់គាត់ចម្រើនវ័យ ក្នុងអំឡុងពេលខ្មែរក្រហមត្រួតត្រា។ តំណាងរបស់ស្ត្រីក្នុងក្រុមប្រឹក្សាឃុំសង្កាត់នៅមានតិច ថ្វីបើកើនឡើងជាបណ្តើរៗពី ៨,៥% នៅឆ្នាំ២០០២ ដល់ ១៥% នៅឆ្នាំ២០០៧ និង ១៧,៨% នៅឆ្នាំ២០១២។ ដោយសារកង្វះខាតថវិការដ្ឋ ឃុំនីមួយៗមានបុគ្គលិកតែស្មៀនឃុំម្នាក់សម្រាប់ជួយ

---

[២] អ្នកតំណាងមកពីគណបក្សនយោបាយខុសៗគ្នា បានឈរឈ្មោះក្នុងការបោះឆ្នោតឆ្នាំ២០១៧។ ប៉ុន្តែការរំលាយគណបក្សជំទាស់ចម្បងគេ បាននាំឲ្យមានការផ្លាស់ប្តូរចេញនូវ សមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សនោះនៅចុងឆ្នាំ២០១៧។ នាបច្ចុប្បន្ន សមាជិកក្រុមប្រឹក្សាឃុំទាំងអស់មកពីគណបក្សប្រជាជនកម្ពុជា។

តារាង១៖ តើអ្នកគិតថា អ្នកទុកចិត្តនរណាខ្លាំងជាងគេ (%)? (N=1600)

| | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ |
|---|---|---|---|---|---|
| ប្រព័ន្ធផ្សព្វផ្សាយ | **12** | 15 | 20 | 29 | 24 |
| ឃុំ | **31** | 30 | 23 | 13 | 4 |
| ប៉ូលីស/តុលាការ | **12** | 22 | 25 | 24 | 13 |
| មន្ទីរពេទ្យ/សាលារៀន | **36** | 26 | 23 | 13 | 5 |
| អ្នកនយោបាយ | **6** | 7 | 10 | 21 | 54 |
| មិនទុកចិត្តមួយណាសោះ | 3 | 0 | 0 | 0 | 0 |

ប្រភព៖ របាយការណ៍ CDRI ស្តីពី យុវជន និងមនុស្សជំនាន់មុន នៅកម្ពុជា, Eng et al. Forthcoming

និងបម្រើការឲ្យក្រុមប្រឹក្សាឃុំសង្កាត់។ នាបច្ចុប្បន្ន ក្រសួងមហាផ្ទៃធ្វើការជ្រើសរើស និងត្រួតពិនិត្យស្មៀនឃុំ។ ថ្វីបើស្មៀនឃុំភាគច្រើននៅក្មេងជាង និងមានការបណ្តុះបណ្តាលល្អជាងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ប៉ុន្តែតែងជាប់រវល់ខ្លាំងនឹងការងាររដ្ឋបាល និងក្រដាសស្នាម ហើយមានពេល និងបទពិសោធន៍តិចសម្រាប់ជួយឃុំ ក្នុងការផ្តួចផ្តើមគំនិតអភិវឌ្ឍន៍មូលដ្ឋាន។ ក្នុងពេលកន្លងមក ទិដ្ឋភាពខ្លះនៃកង្វះសមត្ថភាពគឺមានបុគ្គលិកថ្នាក់ស្រុក ឬថ្នាក់ខេត្តជួយភ្ជិត ជាពិសេសទាក់ទងនឹង ការធ្វើផែនការ ការគ្រប់គ្រងគម្រោង និងការអនុវត្តគោលនយោបាយ។ ទោះយ៉ាងនេះក្តី សមត្ថភាពឃុំសម្រាប់ជំរុញការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍក្នុងមូលដ្ឋាន នៅខ្វះខាតនៅឡើយ បើធៀបនឹងតម្រូវការជាក់ស្តែង។

សំខាន់បំផុត ថ្វីបើគេរំពឹងថា ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវតំណាងឲ្យ និងឆ្លើយតបនឹងសំណើក្នុងមូលដ្ឋាន ប៉ុន្តែក្រុមប្រឹក្សានៅមានការលំបាកក្នុងការអនុវត្តវា។ ដូច្នេះក្រុមប្រឹក្សាត្រូវពឹងផ្អែកស្ទើរតែទាំងស្រុង ទៅលើការគាំទ្រ និងការសម្របសម្រួលពីរដ្ឋអំណាចថ្នាក់លើៗ ដើម្បីផ្តល់សេវា និងអនុវត្តគម្រោងអភិវឌ្ឍន៍ផ្សេងៗក្នុងមូលដ្ឋានខ្លួន។ ទោះបីមានស្ថានភាពបែបនេះក្តី ប្រជាពលរដ្ឋកម្ពុជានៅតែមើលឃើញឃុំ ថាជា កម្រិតរដ្ឋអំណាចគួរឲ្យទុកចិត្តជាងគេ។ ដើម្បីដឹងថា ហេតុអ្វីបានជាវាយ៉ាងដូច្នេះ គេត្រូវពិនិត្យពីបែបបទដែលប្រជាជនក្នុងមូលដ្ឋានធ្វើទំនាក់ទំនងជាមួយរដ្ឋអំណាចឃុំ។

## ទំនាក់ទំនងឃុំ-អ្នកភូមិ

ប្រជាជនកម្ពុជា មានទំនុកចិត្តដូចៗគ្នាទៅលើអាជ្ញាធរឃុំសង្កាត់ ជាងរដ្ឋអំណាចកម្រិតខ្ពស់ៗជាងនេះ។ អង្កេតនៅចុងឆ្នាំ២០១៧ របស់ CDRI លើឥរិយាបទរបស់យុវជន និងមនុស្សជំនាន់មុន ចំពោះស្ថាប័នសាធារណៈ បានបង្ហាញថា ទោះបីមានទំនុកចិត្តកម្រិតទាបជាទូទៅលើស្ថាប័ននានាក្តី ប៉ុន្តែប្រជាជនកម្ពុជាទុកចិត្តឃុំ ច្រើនជាងប្រព័ន្ធផ្សព្វផ្សាយ ប៉ូលីស តុលាការ ឬអ្នកនយោបាយ (Eng et al. Forthcoming)។ អ្នកផ្តល់សេវានៅតាមសាលារៀន និងមន្ទីរពេទ្យ ក៏ទទួលបានទំនុកចិត្តកម្រិតស្រដៀងគ្នានឹងមេឃុំ/ចៅសង្កាត់ដែរ។ សម្រាប់ស្ថាប័នទាំង ៥ ដែលមានចុះក្នុងតារាង១ អ្នកឆ្លើយសម្ភាសន៍ ៣៦% បានប្រាប់ថា ទុកចិត្តសាលារៀននិងមន្ទីរពេទ្យខ្លាំងជាងគេ បន្ទាប់មកមានអ្នកជ្រើសយកឃុំ ៣១%, ប្រព័ន្ធផ្សព្វផ្សាយ ១២%, ប៉ូលីស និងតុលាការ ១២% និង អ្នកនយោបាយ ៦%។ អង្កេតនេះក៏រកឃើញដែរថា ប្រជាជនកម្ពុជាភាគច្រើន (៨៦%) គោរពមេឃុំរបស់ខ្លួន។ ទាំងក្មេងនិងចាស់ ទាំងស្ត្រីនិងបុរស ទាំងអ្នកនៅជនបទនិងទីក្រុង តែងគិតដូចគ្នាក្នុងការគោរពអាជ្ញាធរ ហើយតែងកោតសរសើរ និងគោរពមេឃុំរបស់ខ្លួនជាខ្លាំង (Eng et al. Forthcoming)។

ទំនុកចិត្តកម្រិតខ្ពស់ទៅលើឃុំនេះ ក៏មានរាយការណ៍ក្នុងការសិក្សាពីមុនៗដែរ។ អង្កេតមួយធ្វើឡើងដោយ មូលនិធិអាស៊ី (Asia Foundation) ភ្លាមៗក្រោយការបោះឆ្នោតឃុំសង្កាត់លើកទី១ បានរកឃើញថា អ្នកឆ្លើយសម្ភាសន៍សឹងតែគ្រប់គ្នា (៩៩%) ទុកចិត្តលើអាជ្ញាធរឃុំ ច្រើនជាងមន្ត្រីខេត្ត និងតំណាងរាស្ត្រ (Ninh and Henke 2005, 19) ។ ឥរិយាបទវិជ្ជមានបែបនេះ ក៏រកឃើញក្នុងការសិក្សាពីភាពក្រីក្រដែល CDRI ធ្វើឡើងនៅឆ្នាំ២០០៧ ដែរ។ ការសិក្សាបានរកឃើញថា អ្នកឆ្លើយសម្ភាសន៍ក្នុង ៩ភូមិក្នុងអង្កេត គាត់ទុកចិត្តមន្ត្រីក្នុងមូលដ្ឋាន ច្រើនជាងរដ្ឋអំណាចថ្នាក់លើៗ ដោយមាន ៥២% ទុកចិត្តលើប្រធានភូមិ និង ៤៨% ទុកចិត្តលើក្រុមប្រឹក្សាឃុំសង្កាត់ (FitzGerald and So 2007, 137–138)។

ភស្តុតាងនេះសំខាន់គួរសម ហើយឯកសារមានស្រាប់បានផ្តល់គំនិតពីមូលហេតុខ្លះៗ ដែលអាចនាំឲ្យមានទំនុកចិត្តកម្រិតខ្ពស់លើឃុំ។ គេអាចវែកញែកថា អ្នកភូមិទុកចិត្តលើឃុំ ព្រោះឃុំមានលក្ខណៈបើកចំហជាងរដ្ឋអំណាចកម្រិតផ្សេងទៀត ហើយគាត់តែងគិតថា ឃុំជាទូទៅតែងបម្រើប្រជាជនក្នុងមូលដ្ឋាន។ ប្រជាជនកម្ពុជាភាគច្រើន (៧៣%) ធ្លាប់ចូលរួមក្នុងសកម្មភាព

រូបភាព១៖ តើអ្នកធ្លាប់បានចូលរួមក្នុងសកម្មភាព/ការប្រជុំទាំងនេះឬទេ? (N=1600)




ប្រភព៖ របាយការណ៍ CDRI ស្តីពី យុវជន និង មនុស្សជំនាន់មុន នៅកម្ពុជា, Eng et al. Forthcoming

តារាង២៖ តើអ្នកធ្លាប់ចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះឬទេ? (N=1600)

| | សរុប | ជំនាន់មនុស្ស | | ភេទ | | ទីតាំង | |
|---|---|---|---|---|---|---|---|
| | | យុវជន | មនុស្ស ជំនាន់មុន | បុរស | ស្ត្រី | ជនបទ | ទីក្រុង |
| ការប្រជុំនៅតាមភូមិ | 58 | 37 | 65 | 60 | 57 | 63 | 46 |
| ការប្រជុំនៅថ្នាក់ឃុំ | 37 | 19 | 43 | 44 | 33 | 37 | 38 |
| ការឃ្លាំមើលគម្រោងរបស់ឃុំ | 21 | 13 | 23 | 27 | 16 | 22 | 18 |
| ការប្រជុំនៅសាលារៀន | 31 | 37 | 30 | 32 | 31 | 34 | 25 |
| ការប្រជុំនៅមណ្ឌលសុខភាព | 43 | 37 | 45 | 38 | 46 | 48 | 28 |
| វេទិកាសាធារណៈ | 17 | 10 | 20 | 23 | 13 | 18 | 15 |

ប្រភព៖ របាយការណ៍ CDRI ស្តីពី យុវជន និង មនុស្សជំនាន់មុន នៅកម្ពុជា, Eng et al. Forthcoming

និងការប្រជុំនៅតាមមូលដ្ឋាន (រូបភាព១)។ ដោយឡែកប្រជាជនកម្ពុជាប្រមាណមួយភាគបី (៣៧%) និយាយថា គាត់ធ្លាប់ចូលរួមក្នុងការប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ ហើយ ១៧% ធ្លាប់ចូលរួមក្នុងវេទិកាសាធារណៈផ្សេងៗ (តារាង២)។ ចំណុចសំខាន់គួរកត់សំគាល់ គឺ គម្លាតដែលមាន រវាងយុវជននឹងមនុស្សជំនាន់មុន រវាងបុរសនឹងស្ត្រី រវាងអ្នករស់នៅជនបទនឹងអ្នករស់នៅទីក្រុង ក្នុងបទពិសោធន៍ ធ្លាប់ចូលរួមក្នុងសកម្មភាពនៅតាមមូលដ្ឋាន។ យុវជន តែងបានចូលរួមក្នុងសកម្មភាពនៅតាមមូលដ្ឋានតិចជាងមនុស្សជំនាន់មុន ពោលគឺ យុវជនដែលធ្លាប់បានចូលរួមមានត្រឹម ១៩% ធៀបនឹង ៤៣% សម្រាប់មនុស្សជំនាន់មុន (តារាង២)។ ស្ត្រី និងអ្នករស់នៅទីក្រុង តែងចូលរួមក្នុងការប្រជុំនៅតាមមូលដ្ឋានបានតិចជាខ្លាំង បើធៀបនឹង បុរស និងអ្នករស់នៅជនបទ។

ការស្រាវជ្រាវបែបបរិមាណវិស័យពីមុនការសិក្សានេះ បានផ្តល់គំនិតថា អ្នកភូមិដឹងពីការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់គាត់ ហើយជាទូទៅតែងពេញចិត្តនឹងក្រុមប្រឹក្សា (COMFREL 2007; Kim 2012; Mansfield and MacLeod 2004)។ ការស្រាវជ្រាវរកឃើញថា ឃុំតែងអនុវត្តតាមនីតិវិធី តែងធ្វើសកម្មភាពបម្រើផលប្រយោជន៍របស់ម្ចាស់ឆ្នោត និងចូលរួមចំណែកជួយកែលំអ

ការអភិវឌ្ឍក្នុងមូលដ្ឋាន (Öjendal and Kim 2011; World Bank 2013)។ ម្យ៉ាងទៀតប្រជាពលរដ្ឋតែងចាប់អារម្មណ៍ថា ការប្រើសេវាដែលក្រុមប្រឹក្សាឃុំសង្កាត់ផ្ដល់ឲ្យ តែងងាយស្រួលជាង និងចំណាយអស់តិចជាង ការប្រើសេវារបស់ស្ថាប័នរដ្ឋផ្សេងទៀត។ សំខាន់ដូចគ្នាដែរ ការសិក្សាបែបបរិមាណវិស័យដទៃទៀត បានបង្ហាញថា អ្នកភូមិពឹងផ្អែកជាខ្លាំងទៅលើមេឃុំក្នុងលក្ខណៈគាត់ជាច្រកធ្វើទំនាក់ទំនងជាមួយរដ្ឋអំណាចថ្នាក់លើៗ ហើយអាចជួបគាត់ដើម្បីបានព័ត៌មាន និងបានជំនួយនៅពេលលំបាកទទួលបានសេវាសាធារណៈផ្សេងៗ និងក្នុងការគ្រប់គ្រងស្ថានភាពមានទំនាស់ (Kim 2012; Mansfield and MacLeod 2004)។ ការសិក្សារបស់ CDRI ពីភាពក្រីក្រក្នុង ៩ភូមិ បង្ហាញថា អ្នកភូមិភាគច្រើននៅពេលត្រូវការជំនួយ គាត់ទៅទាក់ទងតែមន្ត្រីក្នុងមូលដ្ឋានប៉ុណ្ណោះ ហើយកម្រទៅហួសពីថ្នាក់ឃុំសង្កាត់ណាស់ (FitzGerald and So 2007, 123-126)។

គេអាចវែកញែកថា ឃុំជាកម្រិតរដ្ឋអំណាចដែលប្រជាជនកម្ពុជាភាគច្រើន មានទំនុកចិត្តថាអាចទាក់ទងចុះឡើងបាន។ ចំណុចនេះអាចមើលឃើញតាម ការប្រើពាក្យហៅដូចសាច់ញាតិ និងការធ្វើវិនិយោគ ក្នុងទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអាជ្ញាធរមូលដ្ឋាន ជាជាងជាមួយស្ថាប័នផ្លូវការ។ ការសិក្សារបស់ CDRI លើអ្នកដឹកនាំនៅតាមមូលដ្ឋានក្នុង ៣ឃុំ បានរកឃើញថា អ្នកភូមិហៅអ្នកដឹកនាំក្នុងមូលដ្ឋាន ដោយប្រើពាក្យសម្រាប់សាច់ញាតិ ដូចជា *មីង ពូ* និង *តា* ដើម្បីសង្កត់ធ្ងន់ពី ភាពជិតស្និទ្ធ និងការស្និទ្ធស្នាល ក៏ដូចជាកាតព្វកិច្ចរបស់អ្នកដឹកនាំក្នុងមូលដ្ឋាន ក្នុងការការពារ និងមើលថែទាំអ្នកភូមិ ដូចជាសមាជិកគ្រួសារធ្វើចំពោះគ្នាទៅវិញទៅមកដូច្នោះដែរ (Thon et al. 2009)។

គួរឲ្យចាប់អារម្មណ៍ខ្លាំងដែរ គឺការសិក្សាបានរកឃើញថា អ្នកភូមិប្រើពាក្យ *ម៉ែ, ឪ* និង *ម៉ែឪ* តែជាមួយអ្នកណាដែលគាត់គិតថា អាចធ្វើបានតាមការរំពឹងទុក ក្នុងការជួយមើលថែទាំអ្នកភូមិ ដូចជាឪពុកម្ដាយដ៏ល្អដែលមើលថែទាំកូន (Thon et al. 2009, 37) ។ អ្នកភូមិតែងហៅប្រធានភូមិម្នាក់ ថា ឪ ដោយលើកថា គាត់ "មិនសូវមាត់ក ចិត្តល្អ" និង "មានតម្លាភាព មិនលោភលន់" (Thon et al. 2009, 39)។ ផ្ទុយទៅវិញ អ្នកភូមិតែងហៅអ្នកដឹកនាំក្នុងមូលដ្ឋាន និងមន្ត្រីរាជការកម្រិតខ្ពស់ៗ ថា *អាជ្ញាធរ* ដើម្បីបង្ហាញពីគម្លាត ភាពមិនសិទ្ធស្នាល និង ការមិនទុកចិត្ត។

ការចូលចិត្តប្រើទំនាក់ទំនងផ្ទាល់ខ្លួន ជាជាងរបៀបរបបស្ថាប័នបង្ហាញថា កំណែទម្រង់វិមជ្ឈការមិនទាន់បានជំនួសនៅឡើយទេ នូវទំនាក់ទំនងក្រៅផ្លូវការនិងជាប្រយោល ឲ្យទៅជាទំនាក់ទំនងប្រកបដោយគណនេយ្យភាព ជាផ្លូវការ និងដោយផ្ទាល់រវាងប្រជាពលរដ្ឋនឹងរដ្ឋ។ ទោះយ៉ាងនេះក្ដី ការប្រើប្រាស់យុទ្ធសាស្ត្រផ្ទាល់ខ្លួនដើម្បីផ្ដល់ ឬដកចេញវិញនូវសិទ្ធិពេញច្បាប់ វាមានឥទ្ធិពលច្រើន ហើយអ្នកដឹកនាំក្នុងមូលដ្ឋានក៏ចាប់អារម្មណ៍ច្បាស់លាស់ដែរ។ វាជាចំណុចមួយដែលមេឃុំយកចិត្តទុកដាក់ខ្លាំងព្រោះការទទួលបាន ភក្ដីភាពពីម្ចាស់ឆ្នោត គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការកៀងគរប្រមូលសន្លឹកឆ្នោត។ ជាឧទាហរណ៍ អង្កេតឆ្នាំ២០១៧ របស់ CDRI បានរកឃើញថា ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មានមនុស្សជំនាន់មុន ៤៤% និង យុវជន ៣៥% បានចាត់ទុកមេឃុំជាមនុស្សសំខាន់ មានតម្លៃស្មើនឹងមិត្តភក្តិ និងជាប្រភពព័ត៌មានផ្នែកនយោបាយ (តារាង៣)។ សំខាន់ជាងនេះទៀត សេចក្ដីសម្រេចក្នុងការបោះឆ្នោត ក៏ជាប់ទាក់ទងនឹងឃុំដែរ។ អង្កេតឆ្នាំ២០១៤ របស់ មូលនិធិអាស៊ី បានរកឃើញថា ប្រជាជនកម្ពុជាភាគច្រើន (៧៤%) ចូលចិត្តទៅបោះឆ្នោតនៅភូមិកំណើត ជាជាងនៅទីកន្លែងដែលខ្លួនរស់នៅ និងធ្វើការជាក់ស្ដែង ទោះបីជាធ្វើដូច្នេះគាត់ត្រូវចំណាយពេល និងសោហ៊ុយអស់យ៉ាងច្រើនក្ដី (Everett and Meisburger 2014, 57)។

## សេចក្តីសន្និដ្ឋាន

មានភស្តុតាងបង្ហាញច្បាស់ថា ក្រុមប្រឹក្សាឃុំសង្កាត់មានប្រជាប្រិយភាព និងទទួលបានការគោរពពីប្រជាជនកម្ពុជាភាគច្រើន ដោយសារតួនាទីគាត់ក្នុងការអភិវឌ្ឍនៅតាមមូលដ្ឋាន ការដោះស្រាយទំនាស់ និងការកៀងគរអ្នកបោះឆ្នោតឲ្យចូលរួមក្នុងការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ទំនាក់ទំនងរឹងមាំបែបនេះកើតមានទៅបាន តាមរយៈភាពងាយជួបទាក់ទង និងការឆ្លើយតបនឹងតម្រូវការក្នុងមូលដ្ឋាន ក៏ដូចជា ការដាក់បង្កប់ទំនាក់ទំនងផ្ទាល់ខ្លួនទៅក្នុង ទំនាក់ទំនងរវាងរដ្ឋ-សង្គម នៅក្នុងមូលដ្ឋាន។ យុទ្ធសាស្ត្រនេះ កន្លងមកមានផលប៉ះពាល់ជាក់ស្ដែងដល់ការកសាងទំនុកចិត្ត ប៉ុន្តែអាចចុះខ្សោយតាមការប្រែប្រួលផ្នែកប្រជាសាស្ត្រ ដោយក្នុងនោះ យុវជនកាន់តែចល័តខ្លាំងឡើង ច្រើនមានការងារនៅតំបន់ទីក្រុង ឬនៅបរទេស និងកាន់តែពឹងផ្អែកលើបណ្ដាញសង្គម ដើម្បីទទួលបានព័ត៌មានផ្នែកនយោបាយ (BBC Media Action 2014; Eng et al. Forthcoming)។

ដោយសារទំនាក់ទំនងផ្ទាល់ខ្លួន បានក្លាយជាបែបបទធម្មតានៃអន្តរកម្មនៅកម្ពុជានោះ ការបង្កើនលក្ខណៈផ្លូវការ និងទំនាក់ទំនងរដ្ឋ-សង្គមតាមច្បាប់គ្រប់គ្រង ជាពិសេស រវាងឃុំនឹងអ្នកភូមិ គឺត្រូវទាមទារមិនគ្រាន់តែការបង្កើតដំណើរការថ្មីក្នុងកំណែទម្រង់វិមជ្ឈការប៉ុណ្ណោះទេ ប៉ុន្តែការផ្លាស់ប្ដូរស៊ីជម្រៅផងដែរនូវអាកប្បកិរិយា និងឥរិយាបទ ទាំងរបស់ប្រជាពលរដ្ឋ និងរបស់មន្ត្រីរដ្ឋាភិបាល។

ការបោះជំហានពិតប្រាកដ សំដៅពង្រឹងទំនុកចិត្តរបស់ប្រជាពលរដ្ឋទៅលើរដ្ឋាភិបាល គួរធ្វើស្របគ្នាជាមួយការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការកែលំអការផ្ដល់សេវា និងលទ្ធផលនៃសេវាវិស័យសាធារណៈ ហើយអាចអនុវត្តទៅបានតាមការបង្កើនភាពឆ្លើយតបរបស់មន្ត្រីរាជការ ការកែលំអតម្លាភាពក្នុងការផ្ដល់សេវាសាធារណៈ និងការជួយសម្រួលថែមទៀតដល់ការចូលរួមសកម្មរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិល ក្នុងដំណើរការធ្វើ

សេចក្ដីសម្រេចចិត្តជាសាធារណៈ។ ដើម្បីជួយពង្រឹងទំនុកចិត្ត រវាងឃុំសង្កាត់នឹងអ្នកភូមិ មានការផ្ដល់មតិមួយចំនួនដូចតទៅ៖

- ត្រូវបង្កើនទឹកប្រាក់នៃការបែងចែកមូលនិធិឃុំសង្កាត់ និងសិទ្ធិអំណាចសម្រេចអារកាត់របស់ឃុំសង្កាត់ ហើយក្នុងពេលជាមួយគ្នា ត្រូវជួយសម្រួលឃុំក្នុងការកៀងគរប្រមូលចំណូលពីប្រភពក្នុងមូលដ្ឋាន ដើម្បីឲ្យមានភាពឆ្លើយតបកាន់តែប្រសើរ
- លើកស្ទួយទំនាក់ទំនងគណនេយ្យភាព រវាងកម្រិតឃុំនឹងស្រុកក្នុងការឆ្លើយតបចំទូលាយរបស់រដ្ឋាភិបាលលើ ការផ្ដល់សេវាសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាន ក្នុងនោះមានទាំងសម្រាប់យុវជនផង
- ជំរុញការចូលរួមចំទូលាយរបស់អ្នកភូមិ និងយុវជន ក្នុងការធ្វើសេចក្ដីសម្រេចសំខាន់ៗ ដោយមានទាំងការចូលរួមជាយុទ្ធសាស្ត្ររបស់អង្គការសង្គមស៊ីវិល និងអាជីវកម្មនានាក្នុងមូលដ្ឋានផង។

## ឯកសារយោង


BBC Media Action. 2014. *Youth in Cambodia: Media Habits and Information Sources*. Phnom Penh: BBC Media Action Research and Learning: 42.

COMFREL. 2007. *Assessment of the First Term of Decentralisation in Cambodia – Commune Council Performance and Citizens' Participation, 2002–2007*. Phnom Penh: COMFREL.

Eng Netra. 2016. "Decentralization in Cambodia: Old Wine in New Bottles." *Public Administration and Development* 36:250–262.

Eng Netra, Ang Len, So Hengvotey, Hav Gechhong and Chhom Theavy. Forthcoming. *Cambodia's Young and Older Generation: Views on Generational Relations, and Key Social and Political Issues*. Working Paper. Phnom Penh: CDRI.

Eng Netra, Vorng Mun and Navy Hort. 2015. *Social Accountability in Service Delivery in Cambodia*. Working Paper Series 102. Phnom Penh: CDRI.

Everett, Silas, and Tim Meisburger. 2014. *Democracy in Cambodia: A Survey of the Cambodian Electorate*. The Asia Foundation. https://asiafoundation.org/resources/pdfs/DemocracyinCa mbodia2014.pdf.

FitzGerald, Ingrid, and So Sovannarith. 2007. *Moving Out of Poverty: Trends in Community Well-being and Household Mobility in Nine Cambodian Villages*. Phnom Penh: CDRI.

Kim Sedara. 2012. "Democracy in Action: Decentralisation in Post-conflict Cambodia." PhD thesis (unpublished), University of Gotheburg, Sweden.

Kim Sedara and Joakim Öjendal. 2011. *Real Democratization in Cambodia? An Empirical Review of the Evolution of the Decentralisation Reform.* Visby: Swedish International Centre for Local Democracy.

Mansfield, Cristina, and Kurt MacLeod. 2004. *Commune Councils and Civil Society: Promoting Decentralization through Partnerships*. Phnom Penh: PACT Cambodia.

NCDDS (National Committee for Sub-National Democratic Development Secretariat). 2012. *Mid Term Review of the Implementation Plan 2011–13 (IP-3) of the National Programme for Sub-National Democratic Development* (NP-SNDD / IP-3). Phnom Penh.

Ninh, Kim, and Roger Henke. 2005. *Commune Councils in Cambodia: A National Survey on Their Functions and Performance, with a Special Focus on Conflict Resolution*. San Francisco: The Asia Foundation in collaboration with Center for Advanced Study.

OECD (Organisation for Economic Cooperation and Development). 2017. *Youth Well-Being: Policy Review of Cambodia*. Report for EU-OECD Youth Inclusion Project Country Review. Paris: OECD.

Öjendal, Joakim, and Kim Sedara. 2011. *Real Democratization in Cambodia? An Empirical Review of the Potential of a Decentralization Reform*. Working Paper No. 9. Swedish International Centre for Local Democracy.

Particip Consortium. 2016. *State of Play – Mid-Term Review of the National Program for Sub-National Democratic Development (NP-SNDD) Cambodia*. Phnom Penh.

Rusten, Caroline, Kim Sedara, Eng Netra and Pak Kimchouen. 2004. *The challenges of Decentralization Design in Cambodia.* Monograph. Phnom Penh: CDRI.

Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem. 2009. *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces.* CDRI Working Paper 42. Phnom Penh: CDRI.

World Bank. 2012. *Voice, Choice, and Decision: A Study of Local Governance Processes*. Washington, DC: World Bank.

World Bank. 2013. *Voice, Choice and Decision: A Study of Local Basic Service Delivery in Cambodia*. Washington, DC: World Bank.